## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តតាកែវ**

-សំណុំរឿងរដ្ឋប្បវេណីលេខ ៣៩៧
ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៣
-សាលក្រមរដ្ឋប្បវេណីលេខ ០៩ "ឋ"
ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៤

# សាលក្រម
## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តតាកែវ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤

**ចៅក្រមជំនុំជម្រះ**

លោកស្រី [redacted] ជាចៅក្រម នៃសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជី**

លោកស្រី [redacted] ជាក្រឡាបញ្ជី នៃសាលាដំបូងខេត្តតាកែវ

**ដើមចោទ:**

ឈ្មោះ [redacted] ចន្ធី ភេទស្រី កើតឆ្នាំ១៩៨៣ ជនជាតិខ្មែរ មុខរបរគ្រូបង្រៀន ទីលំនៅបច្ចុប្បន្នភូមិ [redacted] ។

ដោយមានលោកមេធាវី [redacted] ,លោក [redacted] និងលោកស្រីមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ។

**ចុងចម្លើយ:**

ឈ្មោះ [redacted] សម្ផស្ស ភេទប្រុស កើតឆ្នាំ១៩៨៤ ជនជាតិខ្មែរ មុខរបរគ្រូបង្រៀន ទីលំនៅបច្ចុប្បន្នភូមិ [redacted] ។

## អង្គហេតុ និងចំណុចវិវាទ

### ក.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

១.សុំលែងលះពីប្ដីឈ្មោះ [redacted] សម្ផស្ស ។

២.សុំសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] មង្គលសក្តិយស ភេទប្រុស កើតថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២២ ។

៣.ឱ្យចុងចម្លើយបង់សោហ៊ុយចាំបាច់ ដើម្បីចិញ្ចឹមបីបាច់ និងថែរក្សាកូនជាប្រចាំខែតាមលទ្ធភាព រហូតដល់កូនដល់វ័យនីតិភាព ។

៤.សុំសិទ្ធិគ្រប់គ្រង ប្រើប្រាស់ និងចាត់ចែងលើទ្រព្យសម្បត្តិដោយឡែកនូវម៉ូតូ ០១គ្រឿង ម៉ាក HONDA DREAM125 ពណ៌ខ្មៅ លេខតួ ND125M-8860922 លេខម៉ាស៊ីន ND 125ME-8860922 ស្លាកលេខ ភ្នំពេញ 1BU-7951 ។

៥.សុំសិទ្ធិគ្រប់គ្រង ប្រើប្រាស់ និងចាត់ចែងលើទ្រព្យសម្បត្តិរួមមាន៖

-ទូទឹកកកចំនួន ០២ (ពីរ) ទូដាក់ឥវ៉ាន់ គ្រឿងក្រអូបចំនួន ០២ (ពីរ)



Scanned with CamScanner

-កន្ទុយរ៉ឺម៉កចំនួន ០១ (មួយ)

-រថយន្ត ០១ គ្រឿង ម៉ាក TOYOTA HIGHLANDER ពណ៌ស លេខតួ JTE0021A3501322 លេខម៉ាស៊ីន 2AZ1930082 ស្លាកលេខ ភ្នំពេញ 2AQ-3747 ។

៦.ឱ្យចុងចម្លើយឈ្មោះ [redacted] សម្ផស្ស ជាអ្នកទទួលត្រូវក្នុងការសងបំណុលចំនួន ២.០០០ $ (ពីរពាន់) ដុល្លារអាមេរិក។

៧.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

**ខ.ដំណើររឿងក្តី និងចំណុចវិវាទ**

**ខ.១.ការសង្ខេបអំពីរឿងក្តី**

កាលពីអំឡុងឆ្នាំ២០១៩ ដើមចោទឈ្មោះ [redacted] ចន្ទី និងចុងចម្លើយឈ្មោះ [redacted] សម្ផស្ស បានរៀបការជាមួយគ្នា និងបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ២០ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ ។ បន្ទាប់ពីរួមរស់នៅជាមួយគ្នាអស់រយៈពេលជាច្រើនឆ្នាំមកដើមចោទ និងចុងចម្លើយបង្កើតកូនប្រុសបានចំនួន ០១នាក់ ឈ្មោះ [redacted] មង្គលសក្តិយស និងមានទ្រព្យរួម និងទ្រព្យសម្បត្តិដោយឡែកនូវម៉ូតូ ០១គ្រឿង ម៉ាក HONDA DREAM125 ពណ៌ខ្មៅ លេខតួ ND125M-8860922 លេខម៉ាស៊ីន ND 125ME-8860922 ស្លាកលេខ ភ្នំពេញ 1BU-7951 ,ទូទឹកកកចំនួន ០២ ទូដាក់អីវ៉ាន់ចំនួន ០២ កន្ទុយរ៉ឺម៉កចំនួន ០១ និងរថយន្តចំនួន ០១ ។ លុះនៅអំឡុងឆ្នាំ២០២១ ដើមចោទ និងចុងចម្លើយតែងតែមានរឿងរកាំរកូសរស់នៅមិនចុះសម្រុងនឹងគ្នា មិនទុកចិត្តគ្នា និងមិនចាត់ទុកចុងចម្លើយជាប្រពន្ធនោះទេ មូលហេតុទាំងនេះហើយ ដែលធ្វើឱ្យដើមចោទអស់មនោសញ្ចេតនាជាប្តីប្រពន្ធមិនអាចរួមរស់ជាមួយគ្នាតទៅទៀតបានឡើយ ទើបនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ដើមចោទដាក់ពាក្យបណ្តឹងមកតុលាការតែម្តង ។

**គ.២.អង្គហេតុដែលគ្មានវិវាទ**

**គ.២.១.**ដើមចោទ និងចុងចម្លើយបានរៀបការនឹងគ្នាកាលពីឆ្នាំ២០១៩ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ២០ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ ។

**គ.២.២.**ដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នា ដោយយកដើមចោទជាអ្នកមានសិទ្ធិអំណាចមេបាលើកូនប្រុសឈ្មោះ [redacted] មង្គលសក្តិយស ។

គូភាគីបានពិភាក្សា និងកំណត់អំពីរបៀបចូលជួបប្រាស្រ័យទាក់ទងកូនដោយឱ្យភាគីដែលគ្មានអំណាចមេបាចូលជួបកូនក្នុងរយៈពេល ១ខែម្តង នៅផ្ទះដើមចោទ ដោយត្រូវជូនដំណឹងដល់ដើមចោទជាមុន

**គ.២.៣.**ចុងចម្លើយបានឯកភាពប្រគល់ឡាន ម៉ូតូ ០១គ្រឿង ម៉ាក HONDA DREAM125 ពណ៌ខ្មៅ លេខតួ ND125M-8860922 លេខម៉ាស៊ីន ND 125ME-8860922 ស្លាកលេខ ភ្នំពេញ 1BU-7951 ,ទូទឹកកកចំនួន ០២ (ពីរ) ,ទូដាក់ឥវ៉ាន់ គ្រឿងក្រអូបចំនួន ០២ (ពីរ) ,កន្ទុយរ៉ឺម៉កចំនួន ០១ (មួយ) ទៅឱ្យដើមចោទគ្រប់គ្រង ។

**គ.២.៤.**ដើមចោទបានឯកភាពប្រគល់ឡានរថយន្ត ០១ គ្រឿង ម៉ាក TOYOTA HIGHLANDER ពណ៌ស លេខតួ JTE0021A3501322 លេខម៉ាស៊ីន 2AZ1930082 ស្លាកលេខ ភ្នំពេញ 2AQ-3747 ទៅឱ្យចុងចម្លើយ



Scanned with CamScanner

គ្រប់គ្រង ។

**ឥ.៣.ចំណុចមិនទាស់** : គ្មាន ។

**ឥ.៤.ការអះអាងរបស់គូភាគី**

**ចំពោះការទាមទារត្រង់ចំណុចទី១**

**-ការអះអាងរបស់ដើមចោទ**

មូលហេតុនៃការទាមទារនេះ ដោយសារកាលពីឆ្នាំ២០១៩ ខ្ញុំ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ ។ តាំងពីរៀបការមក ខ្ញុំ និងចុងចម្លើយមិនដែលមានបញ្ហាជាមួយគ្នានោះទេ និងមានកូនប្រុសចំនួន ០១ នាក់ ឈ្មោះ [redacted] មង្គលសក្ដិយស ។ ទើបតែនៅអំឡុងឆ្នាំ២០២១ ចុងចម្លើយបានទៅខ្ចីលុយអ្នកផ្សេងដោយមិនបានប្រាប់ខ្ញុំម្ចាស់បំណុលមកទារលុយ ហើយខ្ញុំសងលុយជំនួសចំនួន ៥,០០០ $ (ប្រាំពាន់) ដុល្លារអាមេរិក ។ ខ្ញុំក៏ធ្លាប់ធ្វើកិច្ចសន្យាជាមួយចុងចម្លើយផងដែរថាកុំឱ្យខ្ចីលុយគេទៀត ប៉ុន្តែចុងចម្លើយនៅតែធ្វើដដែលៗ ទើបបង្កជាការទាស់ពាក្យសម្ដី រស់នៅមិនចុះសម្រុងនឹងគ្នា ។ ចុងចម្លើយមិនបានចាត់ទុកខ្ញុំជាប្រពន្ធនោះទេ ។ នៅពេលមានជម្លោះពាក្យសម្ដីម្ដងៗ ចុងចម្លើយតែងតែចុះចោលខ្ញុំជាញឹកញាប់ ដោយទៅម្ដងចំនួន ០២ ថ្ងៃ ។ ខ្ញុំមិនដឹងថា គាត់ទៅស្នាក់នៅទីណានោះទេ ។ លុះនៅថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០២៣ ចុងចម្លើយបានបែកលំនៅជាមួយខ្ញុំ ដោយមិនមានមូលហេតុ ។ មូលហេតុនេះហើយបានធ្វើឱ្យខ្ញុំអស់មនោសញ្ចេតនាជាប្ដីប្រពន្ធនឹងគ្នាតទៅទៀត ទើបខ្ញុំបានដាក់ពាក្យបណ្ដឹងមកតុលាការតែម្ដង ។

**-ការអះអាងរបស់ចុងចម្លើយ**

ខ្ញុំសូមឯកភាពតាមការទាមទាររបស់ដើមចោទ ខ្ញុំព្រមលែងលះជាមួយដើមចោទ ។ ខ្ញុំ និងចុងចម្លើយពិតជារស់នៅមិនចុះសម្រុងគ្នាប្រាកដមែន ។

**ចំពោះការទាមទារត្រង់ចំណុចទី២**

**-ការអះអាងរបស់ដើមចោទ និងមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ**

មូលហេតុនៃការទាមទារនេះ មូលហេតុដែលកូនខ្ញុំសិទ្ធិគ្រប់គ្រងកូនឈ្មោះ [redacted] មង្គលសក្ដិយស ដោយសារកូនទាំងពីរនៅជាមួយខ្ញុំតាំងពីតូចមក ហើយខ្ញុំក៏ជាអ្នកមើលថែគាត់ផងដែរ ។ ខ្ញុំគិតថា ខ្ញុំមានពេលវេលាគ្រប់គ្រាន់អាចមើលថែពួកគាត់បាន ,អាចផ្ដល់ការសិក្សា និងអប់រំកូនឱ្យក្លាយជាពលរដ្ឋល្អក្នុងសង្គមបាន ។ ម្យ៉ាងវិញទៀត ខ្ញុំក៏មានការងារច្បាស់លាស់ជាមន្ត្រីរាជការ ,លក់ដូរ , បង្រៀនគួរបន្ថែមដែលមានអាចរកប្រាក់ចំណូលជាទៀងទាត់ ចំនួន ១,០០០ $ (មួយពាន់) ដុល្លារអាមេរិក ក្នុង ០១ ខែ ហើយខ្ញុំក៏មានឪពុកម្ដាយចាំជួយមើលថែកូនផងដែរ ពេលខ្ញុំទៅធ្វើការ ។ សព្វថ្ងៃកូនរស់នៅជាមួយខ្ញុំ ។ កន្លងមកខ្ញុំនៅមើលថែកូនបានជាប់លាប់មិនដែលទៅចោលទេ ចំណែកចុងចម្លើយបានមើលថែកូនតែពេលយប់ ប៉ុន្តែមិនទៀងទាត់ទេ ព្រោះគាត់តែងតែចុះចោលខ្ញុំ និងកូនរហូត ។

ពេលនេះ កូនក្ដីខ្ញុំ និងចុងចម្លើយបានព្រមព្រៀងគ្នាកំណត់អ្នកមានអំណាចមេបា និងការបែងចែកទ្រព្យសម្បត្តិរួម ដូចមានកំណត់ក្នុងកិច្ចព្រមព្រៀង ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤ រួចរាល់ ហើយក៏ពុំមានចំណុចវិវាទ



Scanned with CamScanner

តទៅទៀត ពេលគឺកំណត់យកដើមចោទជាអ្នកមានសិទ្ធិអំណាចមេបាលើកូន ។

-ការអះអាងរបស់ចុងចម្លើយ

កន្លងមក ខ្ញុំធ្លាប់បដិសេធការទាមទាររបស់ដើមចោទនៅដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប៉ុន្តែពេលនេះ ខ្ញុំសូមឯកភាពតាមសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលរបស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ហើយខ្ញុំឯកភាពតាមការទាមទាររបស់ដើមចោទ ។ ខ្ញុំសូមបញ្ជាក់បន្ថែមថា ខ្ញុំ និងដើមចោទពិតជាបានព្រមព្រៀងគ្នាកំណត់អ្នកមានអំណាចមេបា ដូចមានកំណត់ក្នុងកិច្ចព្រមព្រៀង ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ២០២៤ ប្រាកដមែន ហើយក៏ពុំមានចំណុចវិវាទតទៅទៀត។

ចំពោះការទាមទារត្រង់ចំណុចទី៣

-ការអះអាងរបស់ដើមចោទ

ចំពោះអាហារកិច្ចចិញ្ចឹមកូន ខ្ញុំឈប់ទាមទារទៀតហើយ ខ្ញុំមិនចង់បាននោះទេ និងសុំឱ្យតុលាការមិនចាំបាច់សម្រេចពីចំណុចនេះ ។

-ការអះអាងរបស់ចុងចម្លើយ

ខ្ញុំសូមខ្ញុំសូមឯកភាពតាមការសេចក្តីថ្លែងការណ៍របស់ដើមចោទ ។

ចំពោះការទាមទារត្រង់ចំណុចទី៤

-ការអះអាងរបស់ដើមចោទ

មូលហេតុនៃការទាមទារនេះ ដោយហេតុថាមូលហេតុដែលខ្ញុំសុំសិទ្ធិគ្រប់គ្រងម៉ូតូនេះ ដោយសារម៉ូតូនេះជាទ្រព្យដោយឡែករបស់ខ្ញុំ ។ ខ្ញុំបានទិញម៉ូតូនេះនៅឆ្នាំ២០១៣ ពីឈ្មោះ [redacted] ចន្ថា តម្លៃ ១៨០០ $ (មួយពាន់ប្រាំបីរយ) ដុល្លារអាមេរិក ។ សព្វថ្ងៃម៉ូតូនេះ ចុងចម្លើយកំពុងប្រើប្រាស់ ។

-ការអះអាងរបស់ចុងចម្លើយ

ខ្ញុំសូមឯកភាពតាមការទាមទាររបស់ដើមចោទ ពីព្រោះម៉ូតូនេះជាទ្រព្យដោយឡែករបស់ដើមចោទប្រាកដមែន ។

ចំពោះការទាមទារត្រង់ចំណុចទី៥

-ការអះអាងរបស់ដើមចោទ និងមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ

មូលហេតុនៃការទាមទារនេះ ដោយសារខ្ញុំទុកសម្ភារៈទាំងអស់នេះ ដើម្បីរកស៊ីចិញ្ចឹមកូន ។ ចំពោះឡាន ដោយសារនៅពេលទិញឡាននេះមានតម្លៃសរុប ១៧,៨០០ $ (មួយម៉ឺនប្រាំពីរពាន់ប្រាំបីរយ) ដុល្លារអាមេរិក គឺយកលុយដែលបានពីការលក់ដីទ្រព្យដោយឡែករបស់ឪពុកម្តាយចែកឱ្យខ្ញុំចំនួន ៥,០០០ $ (ប្រាំពាន់) ដុល្លារអាមេរិក ចំណែកលុយក្រៅពីនេះ គឺជាលុយរវាងខ្ញុំ និងចុងចម្លើយរកស៊ីរួមគ្នា ។ ខ្ញុំគិតថា ខ្ញុំបានចូលលុយទិញឡានច្រើនជាងចុងចម្លើយ ទើបខ្ញុំសុំសិទ្ធិគ្រប់គ្រងតែម្តង ។ សព្វថ្ងៃឡាននេះ គឺនៅខ្ញុំគ្រប់គ្រង ។ ចំពោះកាតគ្រីឡាន គឺមានតែឈ្មោះចុងចម្លើយ ដោយសារចុងចម្លើយជាអ្នកយកប្រាក់ទៅទិញឡាន ហើយពេលនោះខ្ញុំមិនបានទៅជាមួយដើមចោទនោះទេ ។

ពេលនេះ កូនក្តីខ្ញុំ និងចុងចម្លើយបានព្រមព្រៀងគ្នា ដោយដើមចោទយល់ព្រមប្រគល់រថយន្តម៉ាក TOYOTA



Scanned with CamScanner

HIGHLANDER ពណ៌ស លេខតួ JTE0021A3501322 លេខម៉ាស៊ីន 2AZ1930082 ស្លាកលេខ ភ្នំពេញ 2AQ-3747 ទៅឱ្យចុងចម្លើយជាអ្នកគ្រប់គ្រង ។

-ការអះអាងរបស់ចុងចម្លើយ

កន្លងមក ខ្ញុំធ្លាប់បដិសេធការទាមទាររបស់ដើមចោទនៅដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប៉ុន្តែពេលនេះ ខ្ញុំសូមឯកភាពតាមសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលរបស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ហើយខ្ញុំឯកភាពតាមការទាមទាររបស់ដើមចោទ ។ ខ្ញុំសូមបញ្ជាក់បន្ថែមថា ខ្ញុំ និងដើមចោទពិតជាបានព្រមព្រៀងគ្នាបែងចែកទ្រព្យសម្បត្តិរួម ដូចមានកំណត់ក្នុងកិច្ចព្រមព្រៀង ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤ ប្រាកដមែន ហើយក៏ពុំមានចំណុចវិវាទតទៅទៀត។

ចំពោះការទាមទារត្រង់ចំណុចទី៦

-ការអះអាងរបស់ដើមចោទ

ពេលនេះ ចំពោះចំណុចនេះខ្ញុំឈប់ទាមទារទៀតហើយ និងសុំឱ្យតុលាការពុំចាំបាច់សម្រេចទៀតនោះទេ ។

-ការអះអាងរបស់ចុងចម្លើយ

ចំពោះចំណុចនេះ ខ្ញុំសូមឯកភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទ ។

ចំពោះការទាមទារត្រង់ចំណុចទី៧

-ការអះអាងរបស់ដើមចោទ

មូលហេតុនៃការទាមទារនេះ ដោយសារភាគីចុងចម្លើយជាអ្នកធ្វើឱ្យខ្ញុំអស់មនោសញ្ចេតនា និងបង្កបញ្ហាជាច្រើនដល់ខ្ញុំ ដែលធ្វើឱ្យខ្ញុំមិនអាចរស់នៅជាមួយគាត់បាន ទើបខ្ញុំដាក់ពាក្យបណ្តឹងមកតុលាការ ហើយចុងចម្លើយក៏ឯកភាពថា គាត់ពិតជាបានបង្កបញ្ហាឱ្យខ្ញុំប្រាកដមែន ដែលគប្បីចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

-ការអះអាងរបស់ចុងចម្លើយ

ខ្ញុំសូមបដិសេធ ដោយសារដើមចោទជាអ្នកដាក់ពាក្យបណ្តឹង គាត់ចេញប្រាក់ប្រដាប់ក្តីដោយខ្លួនឯង ។

## សំអាងហេតុ

១/.ផ្អែកតាមកំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងកំណត់ហេតុនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដើមចោទបានទាមទារលែងលះពីចុងចម្លើយ ដោយហេតុថាខ្លួនរស់នៅមិនចុះសម្រុងនឹងគ្នា ហើយចុងចម្លើយតែងតែចុះចោលដើមចោទជាញឹកញាប់ ដោយមិនមានមូលហេតុ ។ មូលហេតុទាំងនេះដែលធ្វើឱ្យចំណងអាពាហ៍ពិពាហ៍រវាងដើមចោទ និងចុងចម្លើយត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានទេ ដែលផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ប្រាកដមែន ម្យ៉ាងវិញទៀតចុងចម្លើយក៏ឯកភាពលែងលះជាមួយដើមចោទដែរ ។ ដូចនេះ គប្បីតុលាការសម្រេចឱ្យលែងលះតាមបញ្ញត្តិមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណី ។

២/.ផ្អែកតាមកំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងកំណត់ហេតុនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដើមចោទ និងចុងចម្លើយបានព្រមព្រៀងកំណត់យកម្តាយឈ្មោះ [redacted] ចន្ធី ជាអ្នកមានសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] មង្គលសក្តិយស ភេទប្រុស កើតថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២២ ។ ដូចនេះ គប្បី



Scanned with CamScanner

តុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគីតាមបញ្ញត្តិមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី ។

គូភាគីបានពិភាក្សា និងកំណត់អំពីរបៀបចូលជួបប្រាស្រ័យទាក់ទងកូនដោយឱ្យភាគីដែលគ្មានអំណាចមេបាចូលជួបកូនក្នុងរយៈពេល ១ខែម្តង នៅផ្ទះដើមចោទ ដោយត្រូវជូនដំណឹងដល់ដើមចោទជាមុន ។ ដូចនេះ គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់ភាគីតាមបញ្ញត្តិមាត្រា១០៤០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។

៣/.ផ្អែកតាមកំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងកំណត់ហេតុនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នាប្រគល់ ម៉ូតូ ០១ គ្រឿង ម៉ាក HONDA DREAM125 ពណ៌ខ្មៅ លេខតួ ND125M-8860922 លេខម៉ាស៊ីន ND 125ME-8860922 ស្លាកលេខ ភ្នំពេញ 1BU-7951 , ទូទឹកកកចំនួន ០២ (ពីរ) ,ទូដាក់ឥវ៉ាន់ គ្រឿងក្រអូបចំនួន ០២ (ពីរ) ,កន្ទុយរ៉ឺម៉កចំនួន ០១ (មួយ) ឱ្យដើមចោទមានសិទ្ធិគ្រប់គ្រង ប្រើប្រាស់ និងចាត់ចែង ។ ដូចនេះ គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគីតាមបញ្ញត្តិមាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី ។

៤/.ផ្អែកតាមកំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងកំណត់ហេតុនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នាប្រគល់រថយន្ត ០១ គ្រឿង ម៉ាក TOYOTA HIGHLANDER ពណ៌ស លេខតួ JTE0021A3501322 លេខម៉ាស៊ីន 2AZ1930082 ស្លាកលេខ ភ្នំពេញ 2AQ-3747 ឱ្យចុងចម្លើយមានសិទ្ធិគ្រប់គ្រង ប្រើប្រាស់ និងចាត់ចែង ។ ដូចនេះ គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគីតាមបញ្ញត្តិមាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី ។

៥/.ប្រដាប់ក្តីជាបន្ទុករបស់គូភាគី គប្បីតុលាការសម្រេចតាមបញ្ញតិមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១.ឱ្យដើមចោទឈ្មោះ [redacted] ចន្ទី និងចុងចម្លើយឈ្មោះ [redacted] សម្ផស្ស លែងលះពីគ្នា ។

២.កំណត់យកឈ្មោះ [redacted] ចន្ទី ជាអ្នកមានសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] មង្គលសក្តិយស ភេទប្រុស កើតថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២២ ។

ភាគីដែលពុំមានសិទ្ធិអំណាចមេបាមានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបានក្នុងរយៈពេល ១ ខែម្តង នៅផ្ទះរបស់ដើមចោទ ដោយត្រូវជូនដំណឹងដល់ដើមចោទជាមុន ។

៣.ប្រគល់ម៉ូតូ ០១ គ្រឿង ម៉ាក HONDA DREAM125 ពណ៌ខ្មៅ លេខតួ ND125M-8860922 លេខម៉ាស៊ីន ND 125ME-8860922 ស្លាកលេខ ភ្នំពេញ 1BU-7951 ,ទូទឹកកកចំនួន ០២ (ពីរ) ,ទូដាក់ឥវ៉ាន់គ្រឿងក្រអូបចំនួន ០២ (ពីរ) និងកន្ទុយរ៉ឺម៉កចំនួន ០១ (មួយ) ឱ្យដើមចោទឈ្មោះ [redacted] ចន្ទី ជាអ្នកមានសិទ្ធិគ្រប់គ្រង ប្រើប្រាស់ និងចាត់ចែង ។

៤.ប្រគល់រថយន្ត ០១ គ្រឿង ម៉ាក TOYOTA HIGHLANDER ពណ៌ស លេខតួ JTE0021A3501322 លេខម៉ាស៊ីន 2AZ1930082 ស្លាកលេខ ភ្នំពេញ 2AQ-3747 ឱ្យចុងចម្លើយឈ្មោះ [redacted] សម្ផស្ស ជាអ្នកមានសិទ្ធិគ្រប់គ្រង ប្រើប្រាស់ និងចាត់ចែង ។

៥.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។



Scanned with CamScanner

សាលក្រមនេះ ត្រូវបានប្រកាសនៅសវនាការជាសាធារណៈនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៤ ។ ក្នុងករណីដែលប្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងក្នុងរយៈពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រមនេះ ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា: [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ២រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ខេត្តតាកែវ,ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៤

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner